ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខៈ ២៥៥ ឧវបន ប្រក

# ប្រកាស
## ស្តីពី
## ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ
## នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៩៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញសេចក្តីសម្រេចលេខ៦៩សសរ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងរដ្ឋលេខាធិការប្រចាំការ
- យោងតាមតម្រូវការការងារចាំបាច់

## សម្រេច

**ប្រការ១ .-**

ត្រូវបានបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) ដូចតទៅ៖

១- រូបខ្ញុំ **ហែម វណ្ណឌី** រដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំគ្រប់គ្រងការងាររួមរបស់ក្រសួង ជាពិសេសដឹកនាំចាត់ចែងត្រួតពិនិត្យ និងតាមដានការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលលើរាល់ចំណុចក្រោមសមត្ថកិច្ចរបស់ក្រសួង ឧ.វ.ប.ន. និងដឹកនាំការអនុវត្តការងារកែទម្រង់, និយ័តកម្ម, បញ្ញត្តិកម្ម, ភាពអនុលោម,



៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

ទទួលខុសត្រូវរួមលើដំណើរប្រព្រឹត្តទៅរបស់ក្រសួង និងអង្គភាពស្ថាប័នដែលស្ថិតក្រោមឱវាទក្រសួង រួមទាំងការងារចាត់តាំងបុគ្គលិក និងទទួលដឹកនាំសម្របសម្រួលយន្តការអន្តរក្រសួងផ្សេងទៀត តាមការចាត់តាំងរបស់រាជរដ្ឋាភិបាល។

២-ឯកឧត្តម **ញឹម ខេមរា** រដ្ឋលេខាធិការប្រចាំការ ជួយរដ្ឋមន្ត្រីលើការងារកំណែទម្រង់, និយ័តកម្ម, បញ្ញត្តិកម្ម, ភាពអនុលោម និងជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ និងការិយាល័យច្រកចេញចូលតែមួយ។

៣-ឯកឧត្តម **ហេង សុខគង់** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានកិច្ចការឧស្សាហកម្មនៃអគ្គនាយកដ្ឋានឧស្សាហកម្ម, នាយកដ្ឋានផែនការនិងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមនៃអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម និងជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តពោធិ៍សាត់។

៤-ឯកឧត្តម **សាត សាមី** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ នៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តកំពត។

៥-ឯកឧត្តម **តោគ សុវណ្ណរិទ្ធ** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម និងមជ្ឈមណ្ឌលផលិតភាពជាតិ នៃអគ្គនាយកដ្ឋានឧស្សាហកម្ម និងជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តកំពង់ស្ពឺ។

៦-លោកជំទាវ **ឡាយ ណារីន** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម និងនាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ, ការងារយេនឌ័រ, ការងារចលនាមហាជន, និងការងារក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តកំពង់ចាម។

៧-ឯកឧត្តម **គឹម ទូច** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារអគ្គាធិការដ្ឋាន។

៨-ឯកឧត្តម **ជួន ទន** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ និងនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តសៀមរាប។

៩-ឯកឧត្តម **អ៊ុំ សុថា** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត និងនាយកដ្ឋានគោលនយោបាយទឹកស្អាត នៃអគ្គនាយកដ្ឋានទឹកស្អាត និងជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តកោះកុង។

១០-ឯកឧត្តម **ដាវ អានសាន** រដ្ឋលេខាធិការ ជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី និងជួយសម្របសម្រួលចលនាយុវជនក្រសួង។

១១-ឯកឧត្តម **ស៊ីម ស៊ីថា** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង នៃអគ្គនាយកដ្ឋានទឹកស្អាត។

១២-ឯកឧត្តម **មាន សុតា** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការងារនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម នៃអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម, ការអនុវត្តភារកិច្ចរបស់ក្រសួងក្នុងក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តកណ្តាល។

១៣-ឯកឧត្តម **ទឹម ស៊ីនី** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានបច្ចេកទេសនិងសុវត្ថិភាពឧស្សាហកម្មនៃអគ្គនាយកដ្ឋានឧស្សាហកម្ម និងជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តកំពង់ឆ្នាំង ។

១៤-ឯកឧត្តម **កែ គី** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារវិទ្យាស្ថានស្តង់ដារកម្ពុជា និងជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តស្វាយរៀង។

១៥-ឯកឧត្តម **សយ គីរមៀ** ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានសរុបនិងព័ត៌មាន និងនាយកដ្ឋានផែនការនិងគ្រប់គ្រងទិន្នន័យនៃអគ្គនាយកដ្ឋានទឹកស្អាត និងជួយសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរឧ.វ.ប.ន. ខេត្តឧត្តរមានជ័យ។

១៦-ឯកឧត្តម **សារុន ឫទ្ធា** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារអគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់ និងជួយរដ្ឋលេខាធិការប្រចាំការលើកិច្ចការនីតិកម្មតាមការចាត់តាំង។

១៧-ឯកឧត្តម **ហេង ណាន** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារវិទ្យាស្ថានជាតិវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍។

១៨-ឯកឧត្តម **ភាន ច័ន្ទមេត្តា** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានផ្ទេរបច្ចេកវិទ្យា, នាយកដ្ឋានគ្រប់គ្រងព័ត៌មានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, និងនាយកដ្ឋានសហប្រតិបត្តិការវិស័យវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ នៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

១៩-លោកជំទាវ **ឃុន ទ៉ារី** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីលើការងារសង្គហមិត្ត និវត្តជន កិច្ចការសង្គម ពិធីបុណ្យជាតិនិងកិច្ចការសាសនា។

២០-ឯកឧត្តម **សុន សេខឃាត** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានកិច្ចការសិប្បកម្ម នៃអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម។

២១-ឯកឧត្តម **ចម ឫទ្ធិ** រដ្ឋលេខាធិការ ជួយរដ្ឋមន្ត្រីសម្របសម្រួលការគ្រប់គ្រងការងារនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

**ប្រការ២** .-

ក្រៅពីភារកិច្ចដូចមានចែងក្នុងប្រការ១ ខាងលើ រដ្ឋលេខាធិការប្រចាំការ និងរដ្ឋលេខាធិការ ត្រូវជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រី។

**ប្រការ៣ .-**

តារាងបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីជួយរដ្ឋមន្ត្រីក្នុងការដឹកនាំ គ្រប់គ្រងអង្គភាពចំណុះក្រសួង និងតារាងបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងដើម្បីសម្របសម្រួលណែនាំការងារដឹកនាំរបស់មន្ទីរ ឧ.វ.ប.ន. រាជធានីខេត្ត មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤ .-**

ក្នុងពេលអវត្តមានដោយជាប់បំពេញបេសកកម្មក្រៅប្រទេស ឬសុំច្បាប់ឈប់សម្រាក រដ្ឋលេខាធិការប្រចាំការ និងរដ្ឋលេខាធិការ ត្រូវស្នើសុំរដ្ឋមន្ត្រីផ្ទេរសិទ្ធិជូនរដ្ឋលេខាធិការមួយរូបផ្សេងទៀតឱ្យបំពេញការងារជំនួស ដើម្បីធានានិរន្តរភាពការងារ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

គ្រប់ថ្នាក់ដឹកនាំក្រសួង នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៤ រោច ខែ ស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហេម វណ្ណឌី**

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

# តារាងបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ
# ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
# ដើម្បីជួយរដ្ឋមន្ត្រីក្នុងការដឹកនាំ គ្រប់គ្រងអង្គភាពចំណុះក្រសួង

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ២៩៩ ឧវបក. ប្រក ចុះថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០២៣

<table>
<tr><th colspan="2">ឈ្មោះអង្គភាពចំណុះនៅរដ្ឋបាលកណ្ដាល</th><th rowspan="2">អនុរដ្ឋលេខាធិការ</th><th rowspan="2">រដ្ឋលេខាធិការ</th></tr>
<tr><th>អង្គភាពចំណុះផ្ទាល់</th><th>អង្គភាពចំណុះថ្នាក់អគ្គនាយកដ្ឋាន</th></tr>
<tr><td rowspan="5">អគ្គនាយកដ្ឋានកិច្ចការទូទៅ</td><td>នាយកដ្ឋានរដ្ឋបាល</td><td>ឯ.ឧ. លីវ មិនច័ន្ទ</td><td rowspan="5">ឯ.ឧ. ញឹម ខេមរា</td></tr>
<tr><td>នាយកដ្ឋានបុគ្គលិក</td><td rowspan="2"></td></tr>
<tr><td>នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ</td></tr>
<tr><td>នាយកដ្ឋាននីតិកម្ម</td><td rowspan="2">ឯ.ឧ. សឹម ណារ៉ា</td></tr>
<tr><td>នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន</td></tr>
<tr><td rowspan="4">អគ្គនាយកដ្ឋានឧស្សាហកម្ម</td><td>នាយកដ្ឋានកិច្ចការឧស្សាហកម្ម</td><td>ឯ.ឧ. ហ៊ុល បុណ្ណារិទ្ធ</td><td>ឯ.ឧ. ហេង សុខគង់</td></tr>
<tr><td>នាយកដ្ឋានបច្ចេកទេសនិងសុវត្ថិភាពឧស្សាហកម្ម</td><td>ឯ.ឧ. វ៉ែន គៀហាក់</td><td>ឯ.ឧ. ទឹង ស៊ីនី</td></tr>
<tr><td>នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម</td><td>ល.ជ. ពៅ វិរលក្ខណ៍</td><td rowspan="2">ឯ.ឧ. ភោគ សុវណ្ណរិទ្ធ</td></tr>
<tr><td>មជ្ឈមណ្ឌលផលិតភាពជាតិ</td><td>ឯ.ឧ. យ៉ា ប៊ុនណា</td></tr>
<tr><td rowspan="3">អគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់</td><td>នាយកដ្ឋានទំនាក់ទំនងនិងព័ត៌មាន</td><td rowspan="2">ឯ.ឧ. ព្រហ្ម ដូលីន</td><td rowspan="3">ឯ.ឧ. សារុន ឫទ្ធា</td></tr>
<tr><td>នាយកដ្ឋានវាយតម្លៃទទួលស្គាល់សមត្ថភាពអង្គភាពពិសោធន៍</td></tr>
<tr><td>នាយកដ្ឋានវាយតម្លៃទទួលស្គាល់អង្គភាពវិញ្ញាបនបត្រកម្ម</td><td>ឯ.ឧ. វ៉ែន គៀហាក់</td></tr>
<tr><td rowspan="3">អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម</td><td>នាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម</td><td rowspan="2">ឯ.ឧ. ហ៊ិត ផេង</td><td>ឯ.ឧ. មាន សុភា</td></tr>
<tr><td>នាយកដ្ឋានផែនការនិងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម</td><td>ឯ.ឧ. ហេង សុខគង់</td></tr>
<tr><td>នាយកដ្ឋានកិច្ចការសិប្បកម្ម</td><td>ឯ.ឧ. ម៉ាត់ សារី</td><td>ឯ.ឧ. សុន សេងហួត</td></tr>
</table>

| | | | |
|---|---|---|---|
| អគ្គនាយកដ្ឋានទឹកស្អាត | នាយកដ្ឋានសរុបនិងព័ត៌មាន | ឯ.ឧ. យុត វុត្ថារិទ្ធ | ឯ.ឧ. សយ ភីរម្យ |
| | នាយកដ្ឋានផែនការនិងគ្រប់គ្រងទិន្នន័យ | | |
| | នាយកដ្ឋានគោលនយោបាយទឹកស្អាត | ឯ.ឧ. ចាន់ បូរិន្ទ | ឯ.ឧ. អ៊ុំ សុថា |
| | នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត | | |
| | នាយកដ្ឋានបច្ចេកទេសនិងគ្រប់គ្រងគម្រោង | ឯ.ឧ. ហ៊ុល បុណ្ណារិទ្ធ | ឯ.ឧ. ស៊ឹម ស៊ីថា |
| អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | នាយកដ្ឋានគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឯ.ឧ. ហ៊ុល សៀងហេង | ឯ.ឧ. សាត សាមី |
| | នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ | | |
| | នាយកដ្ឋានផ្ទេរបច្ចេកវិទ្យា | | ឯ.ឧ. កាន ច័ន្ទមេត្តា |
| | នាយកដ្ឋានគ្រប់គ្រងព័ត៌មានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |
| | នាយកដ្ឋានសហប្រតិបត្តិការវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |
| វិទ្យាស្ថានស្តង់ដារកម្ពុជា | នាយកដ្ឋានព័ត៌មាន | ឯ.ឧ. ឡាំ គីមឡេង | ឯ.ឧ. កែ គី |
| | នាយកដ្ឋានបញ្ញត្តកម្ម | | |
| | នាយកដ្ឋានអភិវឌ្ឍន៍ស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់ | ឯ.ឧ. ជា វ៉េង | |
| | នាយកដ្ឋានវិញ្ញាបនបត្រកម្ម | | |
| វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | នាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យា | ឯ.ឧ. គួក ហ៊ីជៀវ | ឯ.ឧ. ហេង ណាន |
| | នាយកដ្ឋានជំរុញអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |
| | នាយកដ្ឋានបណ្តុះបណ្តាលវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |
| | មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ | | |

| | | | |
|---|---|---|---|
| មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ | ឯ.ឧ. ចាន់ សារ៉ន | ឯ.ឧ. ជួន វន |
| | នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ | | |
| | នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម | ឯ.ឧ. លឹម គង់ | ល.ជ. ឡាយ ណារីន |
| | នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ | | |
| អគ្គាធិការដ្ឋាន | | ឯ.ឧ. សឺន សូថា | ឯ.ឧ. គឹម ទូច |
| នាយកដ្ឋានសវនកម្មផ្ទៃក្នុង | | ឯ.ឧ. មុំ ចន្ទតារ៉ា | ឯ.ឧ. ចម បូរិទ្ធ |
| ការិយាល័យច្រកចេញចូលតែមួយ | | | ឯ.ឧ. ញឹម ខេមរា |

**ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រី ទទួលដឹកនាំរួមលើគ្រប់វិស័យ និងទទួលផ្ទាល់៖

- ការងារចាត់តាំងមន្ត្រី, នាយកដ្ឋានបុគ្គលិក
- រដ្ឋាករទឹកស្វយ័ត
- ការសម្រេចប្រគល់កិច្ចសន្យាលទ្ធកម្ម។

**តារាងបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ**
**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
**ដើម្បីសម្របសម្រួលណែនាំការដឹកនាំរបស់**
**មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
ភ្ជាប់ជាឯកសារឧបសម្ព័ន្ធទី២ នៃប្រកាសលេខ ២៩៩ ឧវបក. ប្រក ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ២០២៣

| **ល.រ.** | **រាជធានី/ខេត្ត** | **អនុរដ្ឋលេខាធិការ** | **រដ្ឋលេខាធិការ** |
|---|---|---|---|
| ១ | បន្ទាយមានជ័យ | ឯ.ឧ. ជា វេង | |
| ២ | បាត់ដំបង | ឯ.ឧ. ចាន់សារ៉ន | |
| ៣ | កំពង់ចាម | | ល.ជ.ទ. ឡាយ ណារីន |
| ៤ | កំពង់ឆ្នាំង | | ឯ.ឧ. ទឹង ស៊ីនី |
| ៥ | កំពង់ស្ពឺ | | ឯ.ឧ. ភោគ សុវណ្ណរិទ្ធ |
| ៦ | កំពង់ធំ | ឯ.ឧ. ព្រហ្ម ដូលីន | |
| ៧ | កំពត | | ឯ.ឧ. សាត សាមី |
| ៨ | កណ្តាល | | ឯ.ឧ. មាន សុភា |
| ៩ | កោះកុង | | ឯ.ឧ. អ៊ុំ សុថា |
| ១០ | ក្រចេះ | ឯ.ឧ. យ៉ា ប៊ុនណា | |
| ១១ | មណ្ឌលគីរី | ឯ.ឧ. លឹម គង់ | |
| ១២ | ភ្នំពេញ | ឯ.ឧ. ហ៊ុល បុណ្ណារិទ្ធ | |
| ១៣ | ព្រះវិហារ | ឯ.ឧ. ហ៊ិត ផេង | |
| ១៤ | ព្រៃវែង | ល.ជ.ទ. ពៅ វរលក្ខណ៍ | |
| ១៥ | ពោធិ៍សាត់ | | ឯ.ឧ. ហេង សុខគង់ |
| ១៦ | រតនគីរី | ឯ.ឧ. ឡាំ គីមឡេង | |
| ១៧ | សៀមរាប | | ឯ.ឧ. ជួន វន |
| ១៨ | ព្រះសីហនុ | ឯ.ឧ. សឹម ណារ៉ា | |
| ១៩ | ស្ទឹងត្រែង | ឯ.ឧ. វ៉ែន គៀហាក់ | |
| ២០ | ស្វាយរៀង | | ឯ.ឧ. កែ គី |
| ២១ | តាកែវ | ឯ.ឧ. ចាន់ បូរិន្ទ | |
| ២២ | កែប | ឯ.ឧ. លីវ មិនច័ន្ទ | |
| ២៣ | ប៉ៃលិន | ឯ.ឧ. យុត វុត្ថារិទ្ធ | |
| ២៤ | ឧត្តរមានជ័យ | | ឯ.ឧ. សយ ភីរម្យ |
| ២៥ | ត្បូងឃ្មុំ | ឯ.ឧ. ជឹម ភ័ក្ត្រា | |